**OMI0004**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

**ឡុង ទួក ភេទប្រុស (រស់)**

**តួនាទីៈ អ្នកដឹកជញ្ជូនពីអូរតាសេក ទៅអូរម្ចូ**

**សម្ភាសជាមួយឈ្មោះ ឡុង ទួក អាយុ៣៨ឆ្នាំ ក្រៅប្រវត្តិរូប**

**មុខងារសព្វថ្ងៃៈ ជំទុកទី២ ឃុំត្រពាំងតាវ**

**រស់នៅភូមិទួលស្វាយ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៨**

**សម្ភាសដោយៈ ហ៊ិន សុធានី**

ធានី ៖ ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយកន្លែងមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានតួនាទីប្រមែលប្រមូលឯកសារនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដើម្បីក្រោមការអនុញ្ញាតិពីរដ្ឋាភិបាលយើង ។ ហើយការប្រមែលប្រមូលឯកសារទាំងអស់នឹងគឺ ដើម្បីយកមកធ្វើជាប្រវត្តិសាស្រ្តទុកឲ្យក្មេងជំនាន់ក្រោយបានដឹងពីសម័យខ្មែរក្រហម ហើយនឹងពីការដើម្បីស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះនៅជំនាន់នឹងដែរ ។ ហើយចង់ឲ្យពូជួយរៀបរាប់ប្រវត្តិរបស់ពូនៅសម័យខ្មែរក្រហម ដែលពូបានដឹង ។

ទួក ៖ បើសិនជាគិត៧៥មែនទៅ ខ្ញុំសឹងតែមិនទាន់កើតផងណា ដល់ពេលឆ្នាំ៧៩ខ្ញុំដឹងៗវាអត់ច្បាស់ទៀត ដឹងថាពេលនោះយួនវៃចូលស្រុកខ្មែរយើង អញ្ចឹងខ្មែរយើងរត់មកនៅតាមព្រំដែនប៉ុននឹងឯង អញ្ចឹងក្រោយមកបើសិនប្រវត្តិខ្មែរក្រហមធំៗចំពោះខ្ញុំអត់ដឹងទេ ព្រោះធម្មតាយើងតូចតាច អ្នកណាគេឲ្យទៅក្បែរគេ ។ បើយើងដឹងៗតែអ្នកដែលនៅកងជុំគ្នាដូចខ្ញុំនិយាយម៉េចអញ្ចឹង តាំងពីប្រវត្តិកងពល៥១៩ ហើយខ្ញុំនៅវរសេនាធំ៨០១តែប៉ុននឹងឯង ។ ដឹងថាម៉ាជំនាន់ច្បាំងនឹងនៅឆ្នាំ១៩៨៨នឹង សៀននឹង គាត់បាត់កាំភ្លើង ដល់ពេលបាត់កាំភ្លើងក៏គេឲ្យយកបុគ្គលនឹងសម្លាប់ចោលទៅ ព្រោះក្បត់ជាតិ ។ ដល់អញ្ចឹងពួកខ្ញុំដើរជុំគ្នា សុខចិត្តដាច់ចិត្តសម្លាប់ម៉េចនឹងបាន អាវៀងចង់និយាយថាវាកុំប៉េចកុំប៉ុក ក៏សុខចិត្តថាយកគាត់ទៅ បេះតែបាញ់លេងប៉ុងប៉ាំងគាត់រត់ចោលទៅ ។ ដល់ពេលមកសម័យក្រោយវិញ យើងរយៈពេលគាត់ទៅបាត់២ឆ្នាំ គាត់ក៏ត្រឡប់មកវិញៗ មេៗគាត់ថា“អឺ!ចុះអញឲ្យ(ខ្មោចហ៊ាន)អញឲ្យពួកឯងសម្លាប់អានឹងចោល ម៉េចបានឯងមិនសម្លាប់ចោល ម៉េចក៏មកជួបអញវិញ” “ចុះបើវាមិនលួចខ្លួនវាផង បងឯងទៅសម្លាប់វាម៉េចនឹងកើត” ក៏គាត់អង្គុយ

ម៉េល គាត់ក៏គិតថា“ឯងគ្រាន់បើ បើសិនធ្វើតាមអញខឹងចប់បណ្តោយ”។ បានគាត់និយាយតែប៉ុននឹង ក៏ថាផ្សះផ្សាគ្នាវិញទៅ នៅជាមួយគ្នាវិញទៅ។ ដល់ពេលក្រោយមកដល់ពេលមកដល់ឆ្នាំ៩៣ ក៏អ៊ុនគាត់បោះឆ្នោត អញ្ចឹងក៏បែកបាក់គារហូតតាំងពីនឹងទៅអត់មានបានជួបគ្នាទេ **សឿន**នោះគាត់មិនដឹងទៅនៅណា។ ហើយ**ហាន**នោះក៏គាត់ឈឺស្លាប់ទៅ ខ្ញុំដឹងតែប៉ុននឹងកន្លែងនឹង។

ធានី : ញាណៗនឹងជាប្រធានរបស់ពូដែលបញ្ជាឲ្យ?

ទូក : ហ៊ានៗគាត់ប្រធាន។

ធានី : ហ៊ានប្រធានរបស់ពូ ដែលបញ្ជាឲ្យចាប់ឈ្មោះសឿនយកទៅសម្លាប់?

ទូក : ឲ្យចាប់ឈ្មោះសឿនយកទៅសម្លាប់ចោល។

ធានី : ប៉ុន្តែដល់ពេល២ឆ្នាំក្រោយ អា៨៨ដែលនេះនឹង ក្រោយ២ឆ្នាំសឿននឹង ត្រឡប់មកវិញ?

ទូក : បាទ!

ធានី : ហើយត្រឡប់មកវិញ គាត់ឃើញ គាត់សួរពូវិញ?

ទូក : គាត់ៗសួរម៉េចបានមិនសម្លាប់វាចោល ក៏ពួកខ្ញុំឆ្លើយថាវា រឿងវាអត់ពិត គាត់មិនមែនចង់បាត់ទេរឿងអញ្ចឹងៗ បើសិនជាគាត់មានគំនិត គាត់មកវិញធ្វើអី។

ធានី : ហើយហ៊ាននឹងគាត់ប្រធានវររបស់ពូឬក៏អី?

ទូក : គាត់ប្រធានវរ ដល់អញ្ចឹងដែលឈ្មោះគាត់ហ៊ាន ដល់អញ្ចឹងគាត់សួរថាចុះឯងម៉េចមិនសម្លាប់ ខ្ញុំថាសម្លាប់ម៉េចនឹងកើត បើគាត់មិនមែនរឿងពិតផង។ ហើយដល់គាត់ថា បើសិនអញទុកតាមនឹងកាលនឹងងាប់មនុស្សឥតប្រយោជន៍។ ដល់អញ្ចឹងគាត់ឲ្យនៅជុំគ្នាវិញ។

ធានី : ពូសឿននឹង គាត់មកពីណាវិញ ២ឆ្នាំនឹងគាតទៅណាវិញ?

ទូក : គាត់រត់ទៅសារភាពនៅក្នុង។

ធានី : ទៅខាងណាវិញ?

ទូក : សារភាពជាមួយដែលទាហានរដ្ឋកម្ពុជា។ ដល់ក្រោយមកពួកខ្ញុំចេះតែដើរច្បាំងតាមភូមិនឹងទៅជួបគ្នាៗចិត្តមិនដាច់ក៏ត្រជឡប់មកវិញមក។

ធានី : អញ្ចឹងកាលនឹងគាត់រត់ទៅខាងភូមិណាដែរ?

ទូក : ម្តុំភូមិពងទឹក។

ធានី : ក្នុងស្រុកអី ឃុំអី?

ទូក : ស្រុកអំពិលៗយើងខេត្តឧត្តរមានជ័យនឹង ដល់ពួកខ្ញុំតែងតែដើរទិញអង្ករ ទិញអី គាត់ចេះតែយកឲ្យយូរៗ គាត់ត្រឡប់មកវិញមក។

ធានី ៖ អញ្ចឹងគាត់លែងចូលរដ្ឋកម្ពុជា ត្រឡប់មកខាងពូវិញ?

ទូក ៖ បាទ! ត្រឡប់មកវិញ ដល់ពេលក្រោយមកឆ្នាំ៩៣នឹង អ៊ុនគាត់បោះឆ្នោតនឹង គេមិនស្រុកណាៗទៅនឹងទៅ ហើយដលអញ្ចឹងមិនដឹងស្រុកនៅណាក៏បែកបាក់ក្នារហូតទៅ ។ ហើយ **ហ៊ាន**នឹងគាត់ស្លាប់ហើយ គាត់ឈឺ បើមិនគ្រូនចាញ់ កើតអេដស៍ ម៉ាជំនាន់នឹង បើមិនគ្រូនចាញ់ កើតអេសដ៍មានតែពីរនឹង ហើយគាត់ស្លាប់បាត់ទៅ ។

ធានី ៖ ហើយក្រោយមក សឿននឹងមានត្រឡប់មករកពូវិញអត់?

ទូក ៖ អត់ ។

ធានី ៖ រហូតមកដល់សព្វថ្ងៃ?

ទូក ៖ បាទ! កាលនឹងយើងធម្មតាយើងរត់ណា ដុតពីសង្គ្រាមមកសុទ្ធតែអ្នកក្រីក្រដូចគ្នា គេមិនដឹងទៅរកស៊ីអី យើងមិនដឹងទៅរកស៊ីអី ក៏បែក ចង់និយាយថាបាត់ឯកសារឈើងទៅណា ។

ធានី ៖ អញ្ចឹងកាលនឹង គាត់ស្រុកកំណើតនៅណាដែរពូ សឿននឹង?

ទូក ៖ អត់ដឹងស្រុកនៅណាទេ អត់បានសួរគ្នាផង មិនទាន់បានសួរទេ ។

ធានី ៖ បកក្រោយតិចណា អាកន្លែងក្នុងចន្លោះពី៧៥ដល់៧៩ដែលពូនៅកុមារ កាលនឹងពូអាយុប៉ុន្មានដែរ?

ទូក ៖ ពីឆ្នាំ៧៥នេះ ប្រហែលជាខ្ញុំអាយុ៤-៥ឆ្នាំអី តាមមើលនោះ ហើយបើឆ្នាំ៧៩ ខ្ញុំអាយុប្រហែលជា៨-៩ឆ្នាំអីហើយ ។ កាលមកតាមព្រំដែន ខ្ញុំមកជាមួយកងចល័តនឹង មិនរត់នឹងទាហានឯណា កាលនឹងធម្មតាយើងចេះតែដើ្មល គេថាហ៎!យួនចូលស្រុកហើយ ចេះតែទៅតាមគេមក ។ ពួកខ្ញុំមែនទែន មកធំតាមព្រំដែនទេ ។

ធានី ៖ ហើយអញ្ចឹងពូ កាលពេលនៅឆ្នាំ៧៥នឹងពូនៅកុមារ នៅជាមួយឪពុកម្តាយ ឬមួយក៏នៅជាមួយអ្នកណា?

ទូក ៖ ខ្ញុំនៅជាមួយឪពុកម្តាយខ្ញុំតើ ។

ធានី ៖ នៅជាមួយឪពុកម្តាយ?

ទូក ៖ បាទ!

ធានី ៖ ហើយនៅកន្លែងណាដែរ?

ទូក ៖ ខ្ញុំនៅកំពង់ចាម ។

ធានី ៖ នៅកំពង់ចាម?

ទូក ៖ បាទ! ខ្ញុំនៅស្រុកស្ទឹងត្រង់ ។

ធានី ៖ ស្រុកស្ទឹងត្រង់?

ទូក : បាទ!

ធានី : ភូមិឃុំអី?

ទូក : ភូមិអូរតាសេក ឃុំអូរម្លូរ ។

ធានី : ភូមិអូរតាសេក?

ទូក : បាទ!

ធានី : ហើយពេលពូនៅនឹងគេឲ្យធ្វើអីខ្លះទៅ?

ទូក : ខ្ញុំអត់ធ្វើអីទេ កាលសម័យ៣ឆ្នាំនឹង ខ្ញុំគេឲ្យដើរបរទេះជាមួយចាស់ៗ ដែលគាត់វិញខ្សែវិញអីនឹងយកអន្ទក់ឲ្យគាត់ហូប ប៉ុនមិនមែនខ្ញុំអ្នកបរទេ គេអ្នកបរទេគ្រាន់តែទៅបាន២នាក់ចាស់ៗចេះណា ។ ដល់ពេលឆ្នាំ៧៨ ៧០អីនឹងយួនមិនវៃចូលស្រុកយើង ។ ដល់ក្រោយមកទៀត ដល់ឆ្នាំ៧៩ វៃមក មានម៉ាខាងទន្លេដ្បើលមកថាអូ! ឥឡូវយួនមក ដល់អញ្ចឹងកងចល័តអីទូរនេរ អញ្ចឹងចាបផ្ដើមរត់ ខ្ញុំចាប់ផ្ដើមបែកសាយត្រឹមនឹងបណ្ដោយ បែកម៉ែខ្ញុំមករហូត ។

ធានី : អញ្ចឹងកាលពេល៧៥អីនឹង ពូនៅជាមួយឪពុកម្ដាយអីទេ?

ទូក : បាទ! នៅជាមួយម៉ាក់ខ្ញុំតើ ពុកខ្ញុំតើ ។

ធានី : ចុះឪពុកម្ដាយពូធ្វើអីដែលកាលនឹង?

ទូក : ឪពុកខ្ញុំឈ្មោះជីន ម៉ែខ្ញុំឈ្មោះ សន តែឥឡូវគាត់ស្លាប់អស់ហើយ ។

ធានី : តែកាលនឹងចង់ដឹងថាគាត់ធ្វើអីដែរ?

ទូក : គ្មានធ្វើស្អីទេ គាត់ប្រជាជនធម្មតានឹង ទៅកន្លែងភូមិខ្ញុំមានទីជម្រាវឯណា អាកន្លែងចំកាត់មាត់ញ៉ាបដែរនឹង អូរតាសេក សុទ្ធតែព្រៃ ។

ធានី : អញ្ចឹងកន្លែងនឹងជាស្រុកកំណើតរបស់ពូតែម្ដង?

ទូក : បាទ! ស្រុកកំណើតរបស់ខ្ញុំបណ្ដោយ ។

ធានី : អញ្ចឹងពូរបៀបដូចថាគេហៅៗ កាលនឹងគេហៅប្រជាជនអីដែរ?

ទូក : វា អាប្រជាជន១៧មេសានឹងមិនមែននៅកន្លែងនឹងទេ មានតែគេជម្លៀសមកចូលកន្លែងភូមិខ្ញុំមាន គេជម្លៀសមកពីភ្នំពេញ តែបើថាពួកខ្ញុំមិនមែន១៧មេសា ពួកខ្ញុំអ្នកនៅនឹងហើយ ។

ធានី : ពូអ្នកនៅនឹង?

ទូក : នៅស្រុកកំណើតនៅនឹងហើយ តែធ្លាប់ឃើញដឹងគេថា ដឹងតែពុកខ្ញុំនេះពួក១៧មេសាហើយជម្លៀស១៧មេសា តែគ្រាន់ថាយើង អារឿងអញ្ចឹងៗយើងអត់ដឹងទេ អ្វីដែលយើងកើតទាន់ វាមិនច្បាស់ដែរ ដឹងនិយាយថាម៉េច ។

ផានី : ប៉ុន្តែកាលនឹងពុកពូប្រាប់ពូថាម៉េចខ្លះដែរ?

ទូក : គាត់និយាយថាអញ្ចឹង គាត់ថាដឹងថាពួកនេះមកច្រើនតាមឃុំយើងនេះសំបូរតែអ្នក១៧មេសា ខ្ញុំចំណាំបានតែប៉ុននឹងទេ ។

ផានី : ហើយក្រោយមកមានអ្នក១៧នឹងទៅណាទៅណែ?

ទូក : អត់ដឹងទៅណាទៅណែទេ ។

ផានី : មានបាត់ដែរ ឬក៏នៅតែភូមិជាមួយពូធម្មតា?

ទូក : ខ្លះនៅ ខ្លះមិនដឹងឲ្យមកណាណែទេ ខ្លះក៏នៅទៅ ខ្លះក៏បាត់បង់ទៅ ។ ដល់ពេលចន្លោះឆ្នាំ៧៩ មកនឹង ខ្ញុំមកនៅព្រំដែន ដឹងនៅណាណែទេ យូរវាភ្លេចអាផ្ទះខ្លួនឯងទៀតក៏រកយូរៗទៅ បានដឹងបងបនខ្ញុំដឹងបានបងប្អូនខ្ញុំមកយកទៅ ។

ផានី : អញ្ចឹងពូកាលពេល៧៥ដល់៧៩នឹង គឺពូនៅតែភូមិរបស់ពូនឹង?

ទូក : បាទ! នៅតែភូមិខ្ញុំទេ ។

ផានី : ហើយចុះពូ ឮថាឪពុកពូម៉េចនោះត្រូវបានគេចាប់?

ទូក : ពុកខ្ញុំវានៅសម័យពាឆ្នាំនឹង វាដើមឆ្នាំ៧៨នឹង អញ្ចឹងគាត់ចាស់ហើយ គេឲ្យគាត់ដើរថែផល ត្រួតភ្លឺស្រែនឹង ស្រាប់តែត្រួតៗលេងគេចាប់ពុកខ្ញុំថាពុកខ្ញុំខ្មែរយួន គេយកទៅដាក់គុក៦ ខែៗនឹងបានគេលែងមកវិញ ម៉ាជំនាន់នឹងជាប់គុកប៉ុន្មានទេ ប៉ុនរស់តែពុកខ្ញុំពីរនាក់ទេ ។ ដល់ ពេលឲ្យគេសួរថាម៉េចខ្មែរយួនអីចេះចុះទៅ ។ ហើយម៉ាថ្ងៃៗខ្ញុំឮគាត់និយាយ គេឆក់ខ្សែភ្លើង មួយថ្ងៃពាដង សួរចម្លើយគាត់ ។ ហើយដល់អញ្ចឹងទៅរយៈពេល៦-៧ខែ បានគេលែងគាត់ មកវិញ សុទ្ធតែទារុណទាភហើយ ។

ផានី : កាលនឹងពេលនឹង ពូនៅកន្លែងណាដែរ?

ទូក : ខ្ញុំៗនៅកន្លែងស្រុកកំណើតខ្ញុំ ។

ផានី : ចង់និយាយថា ពេលដែលឪពុកពូត្រូវគេចាប់នឹង ពូនៅតែដឹក ដូចថាដឹកអង្ករដឹកស្រូវអីជា មួយចាស់ៗដែរ?

ទូក : ដឹកៗជាមួយចាស់ៗដឹកគោម៉ានឹមដើរ គាត់ឲ្យជួយឃ្វាលគោឲ្យគាត់ គាត់អ្នកបរទេះដើម្បីដឹក អង្ករឲ្យអ្នកវិញខ្មែរ ដែលគេចាត់តាំងសម័យពាឆ្នាំនឹង វិញខ្មែរ បោចវល្លិ៍ឯលិចកើតនឹង ហើយ ។

ផានី : ហើយដល់ពេលឪពុកពូត្រូវត្រួតស្រូវ?

ទូក : ឪពុកខ្ញុំគេឲ្យថែផល ដែលគេធ្វើបានហើយនឹង ចង់និយាយថាត្រួតភ្លឺស្រែ បិទទឹកបញ្ចូលទឹក អីនឹង ។

ធានី ៖ តែម្នាក់គាត់ទេ?

ទូក ៖ តែម្នាក់គាត់នឹង ។

ធានី ៖ ហើយដល់ពេលគេមកចាប់ៗប៉ុន្មាននាក់ទៅ?

ទូក ៖ គេមកចាប់នឹង ថ្ងៃនឹងមកចាប់ ខ្ញុំស្តាប់បាននៅស្រែវាលនឹងឈ្មោះអ៊ីសារ៉ាំងៗ គាត់អត់ទាន់ស្លាប់ដែរ ថ្ងៃមុនគាត់មកផ្ទះខ្ញុំម្តង ។

ធានី ៖ គាត់នឹងស្រុកកំណើតនៅណាវិញ?

ទូក ៖ គាត់នៅកំពង់ចាមដូចគ្នា ប៉ុនគាត់នៅស្រែវាល ។

ធានី ៖ ហើយចាប់តែពីរនាក់នឹងទេ?

ទូក ៖ ចាប់ទាំងពីរអ្នកនឹង ចាប់ប៉ុន្មាន៣-៤នាក់ ប៉ុនងាប់នៅសល់តែគាត់ពីរនាក់ ។

ធានី ៖ ហើយប៉ុន្មាន ៤ឬក៏៥នាក់?

ទូក ៖ យើងកាលនោះដូចឈ្មោះតា សៀនៗ ដែលស្គាល់តាសៀននឹងហើយ ប៉ុនគាត់ថា អ៊ីសារ៉ាំង គាត់ថាចាប់៤នាក់ ។ ដល់អញ្ចឹងដែលរស់ៗមានតែពុកខ្ញុំ និងអ៊ីសារ៉ាំងនឹងហើយ ។

ធានី ៖ ពេលមកចាប់ដំបូងគេធ្វើម៉េចខ្លះពូ?

ទូក ៖ ខ្ញុំអត់បានដឹងរឿងទេ គេចាប់ ព្រោះគេចាប់កន្លែងគាត់ធ្វើការនោះនឹង តែខ្ញុំផ្សេងម៉េចដឹង ។

ធានី ៖ ចុះម៉េចបានពូដឹងថាឪពុកពូត្រូវគេម៉េចៗ គាត់ប្រាប់ដំណើរដើមទង?

ទូក ៖ ពេលដែលគាត់រួចពីគុកវិញ គាត់មករាយការណ៍ទាំងអស់ គាត់និយាយប្រាប់ណា ។

ធានី ៖ គាត់និយាយថាដំបូងគេចាប់ម៉េចទៅ?

ទូក ៖ អឺ! ដំបូងគេហៅគាត់ទៅបណ្តោយ ក្នុងសម័យនឹងមានកាំភ្លើងឯណាបាញ់សូម្បីតែកាំបិតដាប់ស្រលៀងក៏គេខ្លាច ។ មិនដូចយើងឥឡូវល្មមៗគេចមុខបាត់ឯណា ។

ធានី ៖ គេដំបូង គេមកហៅគាត់ទៅធម្មតាទេ មិនមានចងដៃអីទេ?

ទូក ៖ ដែលគាត់និយាយនឹង គាត់មិនបានចងទេ គ្រាន់តែគេហៅ គាត់ទៅកន្លែងឃុំគេបណ្តោយ ឃុំអូរម្លូ ។

ធានី ៖ ឃុំអីគេ ឃុំអូរម្លូ?

ទូក ៖ បាទ!

ធានី ៖ ហើយអ្នកណាគេមកហៅគាត់?

ទូក ៖ ប្រធានឃុំគេនឹង ប៉ុនមិនដឹងឈ្មោះអីខ្ញុំអត់ដឹងដែរនឹង ។

ធានី ៖ ប្រធានឃុំអូរម្លូនឹង?

ទូក ៖ ហ្នឹងហើយ ។

ធានី ៖ មកហៅផ្ទាល់ម៉ង?

ទូក ៖ ហ្នឹងហើយ ។

ធានី ៖ ហើយមកហៅដាក់នៅកន្លែងណាទៅ?

ទូក ៖ មកហៅទៅនឹង មែនទៅមិនដឹងជាគាត់ទៅកន្លែងណាទេ កាលនឹងខ្ញុំអត់បានសួរច្បាស់ទេ បើអីសាំងមក បានគាត់ដឹងច្បាស់ ជាប់គុកនៅត្រង់ណាចំពោះគាត់អត់ទាន់ស្លាប់ណា ស្លាប់តែពុកខ្ញុំ ។

ធានី ៖ កាលពេលដែលគេមកចាប់ គេហៅគាត់ទៅៗកន្លែងមន្ទីរសន្តិសុខនៅឃុំនឹង ឬមួយក៏ទៅកន្លែងណា?

ទូក ៖ ទៅនឹងឃុំនឹងហើយ ។

ធានី ៖ ទៅនឹងឃុំនឹងម៉ង?

ទូក ៖ បាទ!

ធានី ៖ ហើយអ្នកណាគេអ្នកវ៉ៃឪពុកពូទៅ?

ទូក ៖ ខ្ញុំអត់បានសួរទេកន្លែងនឹង បើអីសាំងមកបានដឹងពីណាៗ ។

ធានី ៖ ប៉ុន្តែពូគិតថាអ្នកណាគេទៅ ព្រោះអីនៅក្នុងមន្ទីរនឹង ហើយប្រធានឃុំអីគាត់អ្នកមកហៅ?

ទូក ៖ វាយើងដឹងអត់ច្បាស់អញ្ចឹងពិបាកនិយាយណាស់ វាមិនដឹងពីណាពិតប្រាកដ ហើយគាត់មិនដែលប្រាប់ពីនេះពីនោះធ្វើបាបគាត់ដែរ ជាប់គុកគេធ្វើចេះៗ ឆក់ខ្សែភ្លើង គាត់បានតែនិយាយប៉ុននឹងឯង ។

ធានី ៖ ហើយគេមានសួរចម្លើយ សួរអីគាត់ដែរ?

ទូក ៖ គាត់សួរ គេសួរៗពីរឿងខ្សែយួននឹងហើយ ។

ធានី ៖ សួររហូត?

ទូក ៖ សួររហូតនឹង សួររកតែគាត់នឹងខ្សែយួន ចុះគាត់ថា«ខ្ញុំដមិនដឹងរឿងនេះទេ» ។

ធានី ៖ ហើយដល់ពេលដែលគាត់ត្រឡប់មកវិញ ពូឃើញសភាពខ្លួនគាត់អីម៉េចដែរ?

ទូក ៖ អឺ! សល់តែស្បែកហើយនឹងឆ្អឹងឡប់មកវិញ តែកូនចៅមើលមិនស្គាល់ ដើរមិនរួចផងនោះ ។

ធានី ៖ ហើយដូចថាពេលដែលគាត់មកអញ្ចឹង គាត់ឈឺអត់ពូ ដូចថាត្រូវសម្រាកប៉ុន្មានថ្ងៃ ប៉ុន្មានខែ ព្រោះគាត់ត្រូវគេវ៉ៃ?

ទូក ៖ អឺ! គាត់ឡើងជរា ឡើងរាប់ខែ ២ខែ ៣ខែដឹងបានដើររួច ។

ធានី ៖ ២ខែ ៣ខែ?

ទូក ៖ បាទ! ធម្មតាតែជាប់គុក មិនមែនដូចសម័យយើងឥឡូវនេះមានបាយហូបខ្វះណាពីសម័យនឹង គាត់និយាយសូម្បីតែសត្វថ្លែងទូកនឹង បែកគ្នាមួយ៣-៤នាក់ ហើយបើសិនពីណាចេញទៅក្រៅអញ្ជឹងគេឲ្យត្រួតចំការចេកអញ្ជឹង មកវិញដុតចេកធ្វើ២មកដល់គេរកឿងទៀត នឹងដៃចេក ។

ធានី ៖ ចុះដល់ពេលឪពុកពូឈឺអញ្ជឹង បានអ្នកណាគេនៅជួយមើលគាត់ហើយគេឲ្យអីគាត់ហូបដែរ?

ទូក ៖ ដល់ពេលគាត់ត្រឡប់មកវិញ អានឹងចង់និយាយថាគេផ្តល់សិទ្ធិឲ្យគាត់ហើយណា ដឹងថាគាត់មិនពាក់ព័ន្ធជាមួយនិន្នាការអីទេ អញ្ចឹងគេឲ្យគាត់ទៅហូបបាយតាមចន្ត្រានធម្មតា ជួនកាលទៅគេយកបាយមកឲ្យគាត់ហូបទៀតហើយ ។

ធានី ៖ អូ! មានបាយហូបដែរ ពូ?

ទូក ៖ ចុះអ្នកមកអញ្ជឹងដំបូងៗគេអ្នកយកបាយ គេបំប៉ន់យើងហើយ មិនមែនឲ្យយើងបាក់ទឹកចិត្តឯណាភ្លាមៗនោះ តែបើសិនអ្នកគិតមិនដល់នោះ វាបាក់ទឹកចិត្តហើយ ។

ធានី ៖ អញ្ជឹងកាលឆ្នាំ៧៨៨នឹង ឪពុកពូត្រូវគេវៃនឹង?

ទូក ៖ បាទ!

ធានី ៖ ហើយគេវៃទៅ គេឲ្យបាយហូបបាយអីក្រោយមក?

ទូក ៖ ក្រោយមក ពីជាប់គុកវិញ បានគេឲ្យបាយហូបធម្មតាវិញ ។

ធានី ៖ អញ្ជឹងនៅភូមិពូហូបបាយ ហូបអីធម្មតាទេ?

ទូក ៖ អត់ទេ ហូបបបរ ។

ធានី ៖ ចុះម៉េចបានគាត់បានហូបបាយ?

ទូក ៖ ចុះមិនញ្ញុំខ្ញុំថាទេ មកដល់អញ្ជឹងធម្មតាគេចង់ប្រើគាត់ទៀត គេមិនធ្វើនយោបាយគាត់ យ៉ាងណាក៏ឲ្យគាត់ហូបឆ្អែតកុំឲ្យមានអារម្មណ៍ចេះចោះ ដែលគាត់ជាប់គុក៦-៧ខែមកហើយ រឿងវាអញ្ជឹង ។

ធានី ៖ ហើយអញ្ជឹងកាលនឹងពូបានហូបបាយជាមួយគាត់ដែរ?

ទូក ៖ ខ្ញុំអត់បានហូបទេ ព្រោះខ្ញុំនៅឆ្ងាយពីគាត់ដែរ មិនមែននៅជុំគាត់ឯណា ខ្ញុំនៅបរទេះនោះគាត់នៅកន្លែង ។

ធានី ៖ អញ្ជឹងគាត់នៅម្នាក់គាត់ទេអញ្ជឹង?

ទូក ៖ បាទ! គាត់នៅកន្លែងធ្វើការ ។

ធានី ៖ ចុះម្ដាយពូ?

ទូក ៖ ម៉ែខ្ញុំគេឲ្យទៅស្ទូងស្រែណាទេ បែកពីគាត់ទៀត អត់នៅជុំគ្នាទេ ។

ធានី ៖ អញ្ចឹងពេលគាត់ឈឺអត់មានអ្នកណាមើលថែគាត់ទេ?

ទូក ៖ មាន បងប្អូនគេនៅជិតៗនឹងមិនអត់ទេ តែគ្រាន់វាសម័យនឹងយើងទៅមានពេទ្យមានថ្នាំណា ដឹកតែថ្នាំឫសឈើលិចកើតនឹង សន្គមកិច្ចគេរកថ្នាំឲ្យគាត់ផឹក តាមសង្កាត់គេនឹងវាមានហើយ មិនមែនអត់ទេ ។

ធានី ៖ អញ្ចឹងសន្គមកិច្ចគេនឹង គេរកថ្នាំឫសឈើនឹងដែរ?

ទូក ៖ នឹងហើយ ។

ធានី ៖ ហើយប៉ុន្មានខែបានគេឈប់ឲ្យ ឲ្យគាត់ហូបបាយរហូត ឬក៏យ៉ាងម៉េច?

ទូក ៖ វា គាត់ហូបបាយនឹងវាមិនយូរទេ ប្រហែលជាកន្លះខែនឹងឯង ហើយដល់ពេលគាត់ស្រួលទៅ គាត់ដើរទៅហូបបបរដូចតែគេនៅចន្ត្រាននឹង ។

ធានី ៖ ប៉ុន្តែគាត់អត់ទាន់ទៅធ្វើការទេ?

ទូក ៖ បាទ!គាត់ធ្វើការ តែគាត់ធ្វើតិចតួចអញ្ចឹង សុំគេសម្រាកខ្លះអីខ្លះ គេក៏យល់យោគគាត់តាមនឹង ។ ដល់ពេលក្រោយមកឈប់ៗពីនឹង ខ្ញុំដឹងថាគេប្រើគាត់ឲ្យទៅរកត្រី ដឹកត្រីម្តង ។ ដឹកត្រីនឹង ដឹកម៉ារទេះសេះទេ ដឹកចេញពីឃុំពាមមក ពាមប្រស្នា បានដឹកឡើងពីនឹងមក ព្រែកសង្កែនឹងមកក្នុងឃុំអូរម្ចនឹង បញ្ជូនត្រីមកដាក់កន្លែងចុងភៅគេ ប៉ុននឹងឯង ។ ដល់ពេលជញ្ជូនមកក្រោយមកចូលឆ្នាំ៧៩ យួនវ៉ៃចូលមកក៏បែកគ្នាត្រឹមនឹងទៅ ។

ធានី ៖ ហើយពូបែកពីឪពុកពូ?

ទូក ៖ ខ្ញុំបែកពីពុកខ្ញុំមករហូតមក ។

ធានី ៖ បែកទៅខាងណាវិញទៅ?

ទូក ៖ ដែលរត់មកព្រំដែននឹង ដល់ស្រុកថៃ ។

ធានី ៖ រត់មកជាមួយអ្នកណាគេ?

ទូក ៖ ជាមួយកងចល័ត ។

ធានី ៖ កងចល័ត ព្រោះកាលនឹងពូនៅខាងកងដឹកជញ្ជូន?

ទូក ៖ អត់ទេ កងចល័តនឹង ឧបមាថាគេធ្វើស្រែត្រង់ណា កងចល័តទៅស្ទូងទៅដក ហើយសុទ្ធតែក្មេងៗ ចង់និយាយថាក្រមុំកម្លោះអីពីជំនាន់នឹង តែពួកខ្ញុំៗនៅក្រៅពីនឹងទេ ។ តែដល់ពេលផ្អើលមក គេអ្នកស្គាល់ៗ គេដឹកដៃខ្ញុំរត់មក ខ្ញុំក៏ទៅតាមគេទៅ ។

ធានី ៖ អ្នកណាគេដែលដឹកដៃពូរត់មកនឹង?

ទូក ៖ ឥឡូវគាត់ទៅស្រុកគាត់ហើយ គាត់នៅតាកែវ ឈ្មោះណិតៗ គាត់នៅតាកែវ ដឹងម៉េចទេ ដឹងស្លាប់ ដឹងរស់ទេ ។

ធានី ៖ ណិតនឹង គាត់មានស្រុកកំណើតនៅតាកែវ?

ទូក ៖ នៅតាកែវ ។

ធានី ៖ ហើយគាត់ស្រី ឬប្រុស?

ទូក ៖ ស្រី ។

ធានី ៖ ស្រី?

ទូក ៖ បាទ!

ធានី ៖ ដឹកដៃពូរត់វិញ?

ទូក ៖ ដឹកដៃខ្ញុំរត់ ។

ធានី ៖ ហើយគាត់នឹងងារធ្វើអីដែរនៅជំនាន់នឹងបាន?

ទូក ៖ គាត់អត់មានងារធ្វើអីទេ គាត់សាមញ្ញធម្មតា គាត់កូនចៅកងចល័តតូចតាចដែរនឹង ធម្មតា យើងដើរជុំគ្នាអញ្ចឹង យើងនឹកឃើញស្រឡាញ់បងស្រឡាញ់ប្អូននោះ កុំឲ្យព្រាត់ប្រាស់គ្នាទៅ តសយើងទៅទាំងអស់គ្នាទៅ ។

ធានី ៖ បបួលគ្នារត់ទៅ?

ទូក ៖ បាទ! បេះតែមកតាមកក្រើកគ្នា រហូតមកដល់តាមព្រំដែន ។

ធានី ៖ ហើយពេលដែល អញ្ចឹងហេតុម៉េចបានពូបានទៅធ្វើកងចល័ត ព្រោះកាលមុនពូប្រាប់ខ្ញុំថាពូ ទៅនៅបរទេះនោះ?

ទូក ៖ អត់ទេ ខ្ញុំនៅបរទេះទេ តែកងចល័តគេនៅធ្វើការក្នុងឃុំនឹង ដល់គ្រាន់ផ្អើលគ្រាប់ ធម្មតាពួក នឹងធំៗជាងយើង "ថាម៉េចគេផ្អើលអីរត់គគ្រឹកគគ្រាក់" ថា"គ្រាប់ផ្លោងមកហើយ យួនចូល មកហើយ" ។រត់ទៅរកម៉ែអត់ឃើញម៉ែ ទៅរកពុកអត់ឃើញ ដល់អញ្ចឹងរត់ទៅតាមគេទៅ ។

ធានី ៖ កាលនឹងពូនៅធ្វើការនៅកន្លែងណាដែល បាន?

ទូក ៖ ខ្ញុំនៅអូរតាសេកនឹង ។

ធានី ៖ នៅភូមិនឹងម៉ង ទៅរកម៉ែរកអី អត់ឃើញ ក៏ទៅតាម?

ទូក ៖ បាទ! ដល់គេបបួលទៅតាមគេបណ្តោយ ។

ធានី ៖ រហូតដល់មក ទៅព្រំដែននឹង កាលនឹងពូទៅខាងច្រកណាវិញ?

ទូក ៖ ខ្ញុំទៅភ្នំឆ័ត្រ ចំការគរនឹង ។

ធានី ៖ នៅក្នុងស្រុកអីគេដែរ?

ទូក ៖ ស្រុកថ្មពួក ស្វាយចេក បណ្តុំត្រង់នឹង ។

ធានី ៖ នៅខាងសៀមរាប ឬក៏ខាង?

ទូក ៖ បន្ទាយមានជ័យ ។

ធានី ៖ ខាងបន្ទាយមានជ័យវិញ?

ទូក ៖ បន្ទាយមានជ័យ ហើយនឹងឧត្តរមានជ័យហើយ ខ្ញុំនៅម្តុំនឹង ។

ធានី ៖ មិនមែនប្រូកនេះទេ ប្រូកខាងបន្ទាយមានជ័យខាងនោះ?

ទូក ៖ មិនមែនឧត្តរមានជ័យទេ បន្ទាយមានជ័យ អាម្តុំយើងហួសបន្ទាយឆ្មារទៅលិចទៀត មកពួកនឹង ម្តុំបឹងត្រកួន ម្តុំអីនឹង ។

ធានី ៖ អានឹងគេហៅប្រូកឈ្មោះអីដែរ?

ទូក ៖ កន្លែងភ្នំឆ័ត្រកន្លែងពួកខ្ញុំនៅ គេហៅភ្នំឆ័ត្រៗចំការគរ ។

ធានី ៖ តែអត់ទៅដល់ថៃទេ?

ទូក ៖ ចុះត្រង់នឹង វាព្រំដែនជាប់នឹងថៃនឹងហើយ ។

ធានី ៖ តែអត់ចូលដល់ថៃណា?

ទូក ៖ អត់ ។

ធានី ៖ ហើយម៉េចបានរត់ទៅដល់នឹងវិញ?

ទូក ៖ ចុះដើរមក មុនដំបូងយើងមកកាត់តាមកំពង់ធំ សៀមរាប មកឡាន មកដល់កន្លែងសៀមរាបនេះ អស់ប្រេងឡានយើងដើរម្តង ដើរកៀកទៅរកទន្លេសាបនោះ ដល់ទន្លេសាបយួននៅនោះត្រឡប់មកនេះ មកតាមផ្លូវនេះវិញ ។

ធានី ៖ តាមផ្លូវណាវិញ?

ទូក ៖ អាតាមផ្លូវយើងលេខ៥នេះ អឺ!លេខ៥ លេខ៦ ។

ធានី ៖ ម៉េចបានរត់មកដល់ខាងភ្នំ?

ទូក ៖ ដល់មកដល់លេខ៥ លេខ៦អញ្ចឹងដឹងគេបានឡានមកពីណាជិះទៅមួយទៀត ទៅដល់យើងចូលមកម៉ាផ្លូវគោកម៉ន ម៉ាផ្លូវស្រុក៧នឹង បាទ!អានឹងចាប់ផ្តើមដើរម្តងហើយ ។

ធានី ៖ ស្រុក៧នៅក្នុងខេត្តអី?

ទូក ៖ ស្រុក៧នៅខេត្តឧត្តរមានជ័យនេះឯង ។

ធានី ៖ ចុះមិញពូថានៅខាងបន្ទាយមានជ័យ?

ទូក ៖ បន្ទាយមានជ័យនឹងរត់ទៅដល់ភ្នំឆ័ត្រហើយស្តាប់បាននៅ អានេះៗគោកម៉ននេះ យើងរត់កាត់ទេ កាត់ពីនឹងទៅ វាបត់បែនច្រើនគ្រលាក់ណាស់ បានទៅចូលទៅអាដែលស្រុកថ្មពួកវិញ ដីស្រុកថ្មពួកវិញ អញ្ចឹងបានឡើងទៅដល់ចំការគ ភ្នំឆ័ត្រនឹងទៅរហូត ។ បានម៉ាជំនាន់នឹងបារាំងគេដឹកអង្ករដឹកអីមកបើក ហូបអាអង្ករបារាំងបើកនឹងឯង ។

ធានី ៖ ទៅដល់ព្រំដែននោះ?

ទូក ៖ បាទ!

ធានី ៖ កន្លែងនឹងគេហៅភ្នំឆ័ត្រ គេមិនមែនអត់មានជំរុំអីទេ?

ទូក ៖ អត់មានជំរុំអី ខ្មែរយើងនៅ ម៉ាចំហៀងប៉ាវ៉ា ម៉ាចំហៀងខ្មែរក្រហមទៅ ។

ធានី ៖ កាលនឹងពូនៅខាងណាដែរ?

ទូក ៖ ខ្ញុំនៅខ្មែរក្រហម ។

ធានី ៖ កាលនឹងអ្នកណាអ្នកគ្រប់គ្រង?

ទូក ៖ ម្តុំត្រង់នឹងមានតែតាសារឿន តាហុង ។

ធានី ៖ តាសារឿង ឌុចសារឿន?

ទូក ៖ ឌុល សារឿន ។

ធានី ៖ ឌុល សារឿន ហើយរាល់ថ្ងៃនឹងគាត់នៅរស់ទេ?

ទូក ៖ នៅរស់តើ ។

ធានី ៖ នៅត្រង់ណាវិញ?

ទូក ៖ គាត់នៅឯស្វាយនឹង ផ្ទះគាត់ ។

ធានី ៖ ស្វាយអីគេពូ?

ទូក ៖ ស្វាយស៊ីសាផុននឹង អាខេត្តបន្ទាយមានជ័យនឹងឯង ។

ធានី ៖ នៅទីរួមខេត្តម៉ង?

ទូក ៖ បាទ!

ធានី ៖ នៅខាងណាដែរ នៅភូមិ ឃុំអី?

ទូក ៖ ទេ! ខ្ញុំអត់ដឹងភូមិ ឃុំអីទេ គ្រាន់ដឹងថាគាត់នៅស្វាយនឹង គាត់ទៅធ្វើចំការនៅជិតម៉ាល័យនោះ ទៅវិញដីគេធ្វើចំការ ក្រោយផ្តាច់យួនមក គាត់នៅនឹង ។

ធានី ៖ ចុះម៉េចបានពូមកនៅខាងនេះ ដែលថាពូបានជួយអ្នកនេះ អ្នកនោះអីរឿងប្រវត្តិ?

ទូក ៖ អានឹងមានរឿងមួយទៀត កាលនោះម៉ាជំនាន់បោះឆ្នោតនឹង រដ្ឋកម្ពុជានិងប៉ាវ៉ាបានត្រូវគ្នា ខ្មែរក្រហមធ្វើវាការមិនចូលបោះឆ្នោតទេ ដល់អញ្ចឹងពួកខ្ញុំក៏នៅនឹង ប៉ាវ៉ាវៃមក វៃបែកភ្នំឆ័ត្រ បានតាម៉ុកនេះមកដឹកពួកខ្ញុំយកមកនៅនឹងអន្លង់វែងនេះ បានរឿងខ្ញុំបានមកនៅអន្លង់វែង កុំអីខ្ញុំមិនដែលស្គាល់អន្លង់វែងទេ ។

ធានី ៖ អញ្ចឹងតាម៉ុកគាត់អ្នកដឹកនាំទ័ពពូ កាលនឹងប៉ុន្មាននាក់ទ័ពនៅឆ័ត្រនឹង?

ទួក ៖ អឺ! មនុស្សវារត់វាច្រើនណាស់ ប៉ុនវាបែកបាក់វា អាខ្លះគេទៅផ្ទះគេក្នុងទៅ អាខ្លះវាទៅខាងម៉ាល័យប៉ៃលិនទៅ អ្នកខ្លះទៅនៅបន្ទាន់ៗ ដែលភ្នំឆ័ត្រដុកគីនឹងក៏តាម៉ុកប្រមូលមកនៅនឹងអន្លង់វែងយើងទាំងអស់នឹង ។

ធានី ៖ ហើយចុះពូអត់បានជួបឪពុកម្តាយពូទេ?

ទួក ៖ អត់ ។

ធានី ៖ ចុះដល់ពេលមកនៅកន្លែងតាម៉ុកនឹងប៉ុន្មានឆ្នាំ?

ទួក ៖ ខ្ញុំនៅកន្លែងតាម៉ុកនឹងមកចាប់ពីឆ្នាំ៩៨មកនឹង ។

ធានី ៖ អូ! ទើបនឹង៩៨នេះទេ?

ទួក ៖ បាទ!កាលមុនខ្ញុំនៅឯលិចនោះទេ ។ ដល់ពេល៩៨ ៩៥ ខ្ញុំបានប្រពន្ធនៅនឹងកន្លែងនឹងទៅ ។

ធានី ៖ អំឡុងពេលដែលពូរត់នឹង រហូតដល់ថៃដល់អីអញ្ចឹង ពូដែលធ្លាប់ជួយអ្នកណាផ្សេងនៅក្នុងអំឡុងពេលនឹងទេ?

ទួក ៖ វាកាលនោះអត់ទេ មែនមនុស្សយើងគឺសម័យនឹង យើងក្តាប់ស្រួលរកតែរស់រៀងខ្លួនទេព្រោះយើងសូម្បីតែស្អីហូបតែយើងគានដែរ ទើបបារាំងយកអីមកបើក ។ ហើយបើកនឹងបានតែស្រីៗទេ ប្រុសៗអត់ឲ្យទេ ។

ធានី ៖ អញ្ចឹងធ្វើម៉េចបានអីហូបទៅ?

ទួក ៖ ចុះធម្មតាយើងចេះក្លែងបន្លំ មិនអញ្ចឹង អាខ្លះធ្វើស្រីធ្វើប្រុសពេញតែវាលនឹង ឲ្យតែបានហូបសិនទៅ ។ ហើយក្នុងនឹងក្នុងកម្ពុជាប្រជាធិបតេយ្យនឹងក៏ចេះតែផ្តល់របស់របរ អង្ករមកអីហូបដែរ តែគ្រាន់តែវាល្មមៗវាមិនគ្រប់គ្រាន់អីទេ យើងទើបនឹងរត់ម៉ាឆុលទៅនឹង ។ ក្រោយមកចូលឆ្នាំ៨១ ៨២ ៨៣បានខ្មែរក្រហមនឹងចិនជំនួយមកពេញទំហឹង អារឿងអង្ករ រឿងស្បៀងនឹង បានមានហូបគ្រប់គ្រាន់ ។

ធានី ៖ ហើយដល់ពេលដែលពូ ពេលដែលឆ្នាំ៩៨ បានមកខាងនេះវិញ ។ ចុះឆ្នាំណាដែលពូបានជួយគាត់ឲ្យដេញមក កាលពេលតាសារឿងនៅភ្នំឆ័ត្រកាលពេញឆ្នាំ៨៨ទេ?

ទួក ៖ បាទៗ ។

ធានី ៖ អញ្ចឹងបានន័យថា មុនដំបូងតាសារឿន ដល់ក្រោយមកបានតាម៉ុកនៅឆ្នាំ៩៨ទេ ក្រោយមកនេះទេ?

ទួក ៖ តាម៉ុកមែនទែន គាត់ធំជាងតាសារឿននឹងទៀត តាសារឿននឹងគាត់តូចតាចទេ ។

ធានី ៖ អញ្ចឹងតាម៉ុកលើ មេតាសារឿនទៀត?

ទួក ៖ មេតាសារឿននឹងទៀត អឺ!មេតាសារឿនកាលនឹង មានតាម៉ុក ប៉ុលពត អៀងសារី សុន

សេនអីអញ្ចឹងពីលើនឹង គាត់ជាមនុស្សតូចតាច ។

ធានី ៖ ពេលពូនៅភ្នំត្រនឹង ខស្សាហ៍ឃើញតាម៉ុកអីមកមើល?

ទូក ៖ អត់ទេ ខ្ញុំមិនដែលបានឃើញផង ទើបមកអន្លង់វែងនេះ បានឃើញស្គាល់តាម៉ុក កាលនឹង មិនដែលស្គាល់ទេ ។

ធានី ៖ ហើយមកដល់នេះ តាម៉ុកគាត់ធ្វើម៉េចខ្លះ?

ទូក ៖ អឺ! តាម៉ុកគាត់និយាយ ចង់និយាយថាគាត់និយាយគ្មាននយោបាយដូចយើងតាម៉ាត់តាម៉ុយ គាត់គ្មាននិយាយទេ បើថាទៅច្បាំងគ្រាន់ថា«អឺ!ពួកឯងបើមិនច្បាំងអញវត់ចោលក្បាលឯង ហើយ» ។

ធានី ៖ អូ! គាត់និយាយតែប៉ុននឹង?

ទូក ៖ ហ្នឹងហើយ ឯងគិចមិនមែនប្រទេសខ្មែរ ដាក់ប្រទេសយួន ។

ធានី ៖ ហើយទៅច្បាំងជាមួយអ្នកណាគេ?

ទូក ៖ ចុះមានស្អី មានតែវៀយួន នឹងទាហានខ្មែរនឹងឯង ។

ធានី ៖ ពីឆ្នាំណាដែរ?

ទូក ៖ ចុះក្រោយពីបោះឆ្នោតហើយ មានឆ្នាំ៩៤ ៩៥ ៩៦ ៩៧នឹងឯង ដល់ពេលមកដល់៩៨ ៩៩ បានដួាច់ខ្លួនទាំងអស់គ្នាបណ្តោយ ។

ធានី ៖ អញ្ចឹងចន្លោះ៩៤ ៩៥អីនឹង គឺពូគិតថាឲ្យទៅវៃជាមួយយួន?

ទូក ៖ តាម៉ុកគាត់ហៅទៅប្រជុំដែរ គ្រាន់តែប្រជុំគាត់មិននិយាយដូចយើងគោរពត្រឹមត្រូវណា ចុះ មកដល់ថា«នែក!ពួកឯងតែមិនខំប្រទេសនេះមិនមែនប្រទេសខ្មែរ ប្រទេសយួនហើយអនាគត ទៅ អញមុខតែវត់ចោលក្បាលទៅ» ។

ធានី ៖ គាត់និយាយអញ្ចឹង?

ទូក ៖ គាត់និយាយតែ២-៣ម៉ាត់ ក៏ជិះឡានទៅបាត់ទៅ ។

ធានី ៖ ហើយដល់ពេលពូត្រូវខំអីទេ?

ទូក ៖ គាត់និយាយឲ្យយើងខំច្បាំងគ្នា ចង់និយាយដណ្តើមទឹកដី គាត់និយាយអញ្ចឹង តែធម្មតាទេ វារឿងនៅក្នុងសង្គមមួយណា បើសិនយើងមិនធ្វើវាមានបញ្ហា សូម្បីតែស្រើៗនៅក្រោយ នេះ គេប្រើបិទចំរូងមួយថ្ងៃៗ មិនដែលបានទំនេរផង អ្នកស្រុកអន្លង់វែងនេះ ។

ធានី ៖ គេឲ្យធ្វើដែរ?

ទូក ៖ បាទ! អញ្ចឹងបានថាយើងចង់ដឹងរឿងពិតសួរតែពូដេត តាម៉ុកម៉េចៗដឹងហើយ ពូដេកគាត់ បាននៅនឹង ខ្ញុំនៅក្រោយគាត់ទេ ។

ធានី ៖ ពូមានឈ្មោះអីដែរ?

ទូក ៖ ខ្ញុំឈ្មោះទូក ។

ធានី ៖ អីគេទូក?

ទូក ៖ ឡុង ។

ធានី ៖ ឡុង ទូក?

ទូក ៖ បាទ! ប៉ុនកាលដែលខ្ញុំដាក់ក្នុងប្រវត្តិរូបខ្មែរក្រហម ខ្ញុំដាក់ជីន ។

ធានី ៖ ជន ទូកវិញ?

ទូក ៖ ពុកខ្ញុំៗដាក់ត្រកូលពុកខ្ញុំផ្ទាល់ នេះខ្ញុំដាក់ជីតាខ្ញុំវិញ ។

ធានី ៖ អញ្ចឹងពូធ្លាប់ធ្វើប្រវត្តិរូបដែរ?

ទូក ៖ ធ្លាប់តើ ។

ធានី ៖ ឆ្នាំណាដែរ?

ទូក ៖ កាលពីរបបខ្មែរក្រហមនឹង កាលនឹងគេដាក់យកតែត្រកូល សួរថាជីតាឈ្មោះអីដាក់តែជីនៗនឹងទៅ គេសួរដែរ គេសួរស្រុកកំណើតយើងនៅណា យើងប្រាប់តាមដំណើរ ដូចខ្ញុំនិយាយមិញនឹង ។

ធានី ៖ ហើយសព្វថ្ងៃពូអាយុប៉ុន្មាន?

ទូក ៖ អាយុ៣៨ហើយ ។

ធានី ៖ អញ្ចឹងជីតាឪពុកពូឈ្មោះឡុង ជីន?

ទូក ៖ ដែលឪពុកខ្ញុំនោះ គាត់ឈ្មោះសេក ខ្ញុំដាក់ជីតាខាងម៉ែខ្ញុំទេ ។

ធានី ៖ ចាស! ឪពុកពូឈ្មោះសេក ជីន?

ទូក ៖ សេក ជីន ។

ធានី ៖ ហើយម្តាយពូ?

ទូក ៖ ឡុង សន ។

ធានី ៖ សព្វថ្ងៃពូមានកូនប៉ុន្មាននាក់?

ទូក ៖ ប្រុស២ ប្រុស៣ ស្រី២ ។

ធានី ៖ ហើយប្រពន្ធពូឈ្មោះអី?

ទូក ៖ ប្រពន្ធខ្ញុំឈ្មោះ ជន ជីម ។

ធានី ៖ ហើយគាត់ធ្វើអីដែរ សព្វថ្ងៃ?

ទូក ៖ អត់មានធ្វើអីទេ ។

ធានី ៖ ដល់ពេលពូ?

ទូក ៖ ខ្ញុំធ្វើជំទុកទី២ឃុំ ។

ធានី ៖ ជំទុកទី២ ?

ទូក ៖ បាទ!

ធានី ៖ ហើយពូមានគ្រួសារនៅឆ្នាំប៉ុន្មាន?

ទូក ៖ ៩៥ ។

ធានី ៖ អញ្ចឹងនៅក្នុងពេលដែលតាម៉ុកគ្រប់គ្រង?

ទូក ៖ បាទ! អញ្ចឹងខ្ញុំឆ្ងល់ថាសួរនឹងក្នុងគោលបំណងយ៉ាងម៉េចៗ វាពាក់ព័ន្ធនៅលើស្អី ខ្ញុំចង់ដឹងប៉ុននឹងដែរ?

ធានី ៖ ពួកខ្ញុំគ្រាន់ចង់ដឹងថា ព្រោះពូធ្លាប់ជួយឲ្យមនុស្សម្នាក់ឈ្មោះសឿន ឲ្យរួចជីវិតអីអញ្ចឹង ហើយពួកខ្ញុំទៅរកអ្នកដែលបានផ្ដល់អញ្ចឹង បានជួយអ្នកដទៃឲ្យរួចជីវិតដល់សព្វថ្ងៃអញ្ចឹង ។ នៅក្នុងរបបខ្មែរក្រហមដែលគាត់បានធ្វើការ ហើយបានជួយគេជួយអីអញ្ចឹង ។

ទូក ៖ ខ្មែរក្រហម ខ្ញុំនិយាយសាច់រឿងវាយ៉ាប់ណាស់ ឆ្ងាយកាលពីមិនទាន់រំលាយបក្សកុម្មុយនីសខ្មែរក្រហម សូម្បីតែជក់បារីក៏គេសង្ស័យដែរ គេសួរពីយើងបានលុយពីណាចាយ ហើយបានលុយស្អីទិញបារីជក់នៅដៃនឹង ។ ការពិតចង់និយាយថាផ្លែគ្រប់ គេបើមកយើងហូបមិនអស់ យើងមិនលក់ឲ្យថៃវិញ ស្រាប់តែទុកចោលទៅវាមិនស្អុយទៅ ។ ខ្ញុំថាឥឡូវអត់យកលុយទេ លុយថៃ លុយបាតនឹងកាក់ៗម៉ាបាត២បាត ខ្ញុំថាឥឡូវឲ្យបារីខ្ញុំម៉ាកញ្ចប់បានហើយ គ្រាន់តែជក់បារីក៏គេសង្ស័យដែរ អាខ្លះវាអាណិតវាឲ្យស្លុរគ្រាប់មកយើងៗអញ្ចុងទៅ ខ្លះគេឲ្យបារី ដល់អញ្ចឹងមេៗសួរថា“ម៉េចឯងបានបារីនឹង បានលុយពីណាទិញ” ថាយើងមិនដឹងនិយាយមិញ ចុះមនុស្សគ្រង់ៗដែរ“ខ្ញុំយកគ្រប់នឹងឯង យកទៅឲ្យថៃវិញ ទុកវាទៅរលួយប៉ុណ្ណោះឯង” ដល់អញ្ចឹងថា“ថ្ងៃក្រោយកុំយកទៅបំផ្លាញអញ្ចឹង” ។ យើងទុកម៉ាត់ទៅចេះគាត់ថាអញ្ចឹងយើងចេះតែសំងំទៅ ។

ធានី ៖ តាសារឿននឹងស្គាល់ឲ្យពូ?

ទូក ៖ ខ្មោចហ៊ាននឹងហើយ សួរពួកខ្ញុំថាពួកខ្ញុំយករបស់ហូប យកទៅឲ្យដូរបំផ្លាញ បើយើងធ្វើម៉េចវា ប្រទេសយើងវាអញ្ចឹងហើយ បើយើងគិតទៅក៏គាត់គ្មានចង់ធ្វើអញ្ចឹងដែរ គាត់យល់ពីសព្វថ្ងៃ ។

ធានី ៖ អញ្ចឹងអរគុណពូច្រើន ។

ទូក ៖ បាទៗ ។ អាខ្លះគេថាចង់ទៅនៅប្រទេសទី៣ ទៅដល់ថ្ងៃរួចហើយ យើងជូនគេទៅគគោក

ហើយ ។

ធានី : គាត់មកពីណាខ្លះដែរ?

ទូក : មនុស្សវាអត់ស្គាល់គ្នា អាខ្លះក៏មកពីភ្នំពេញ ខ្លះមកពីស្វាយរៀងខ្លះមកពីស្រុកយួនបណ្ដោយ

ធានី : ស្គាល់ឈ្មោះគាត់ទេ?

ទូក : អត់ស្គាល់ទេ ។

ធានី : ប៉ុន្មាននាក់ទៅ?

ទូក : ច្រើនណាស់ ម្ដង១០ ម្ដង២០ អាខ្លះម៉ាថ្ងៃនឹង៣០-៤០នាក់ក៏មាន រត់ទៅនៅស្រុកក្រៅនឹង ។

ធានី : ហើយពូជូនគាត់ទៅដល់ថៃ?

ទូក : ជូនទៅដល់ស្រុកថៃបណ្ដោយ ព្រំប្រទល់ថៃឲ្យគាត់ទៅៗ ហើយយើងមកវិញមក ។

ធានី : ហើយតែម្នាក់ពូទេ ហើយមានអ្នកផ្សេង?

ទូក : មិនទេ មនុស្សគគោកនឹង មនុស្សម៉ាកង៣០០-៤០០នាក់នឹង ។

ធានី : ទៅទាំងអស់?

ទូក : ធម្មតាទៅហើយនិងមក មិនចោរប្លន់ឆាប់អស់ហើយពីសម័យនឹងនោះ សម័យគេរត់ពន្ធតាមប្រកខាងម្ដុំគោកធ្លូង ម្ដុំជំរុំចាស់ជំរុំថ្មីនឹង ម៉ាជំនាន់នឹងខ្មែរយើងរត់ពន្ធមានតែគ្រឿងនឹងដៃនេះទេ ។

ធានី : អញ្ចឹងពូដែលជួបៗអ្នកខ្មែរដែលរត់ពន្ធ?

**ខាង«ខ»**

ទូក : ប្រើឲ្យតែមាសឲ្យ៤-៥ជីអីទៅបាន គ្នា៤-៥នាក់យើងចេះតែជូនទៅ ។

ធានី : ហើយគាត់មក រត់ពីខាងណាមកវិញ ដែលមកចូលមកដល់កន្លែងពូនឹង ហើយពូជូនទៅ?

ទូក : វា ខ្ញុំសួរទៅភាគច្រើនមកពីភ្នំពេញ មិនដឹងគាត់នៅឃុំអី ខេត្តអី ខ្ញុំអត់បានសួរទេ ។ ហើយពេលដែលយើងជូននឹង មេធំៗក៏មិនដឹងដែរ ដឹងថាតូចតាច សិទ្ធិត្រឹមកងតូចកងធំយើងចេះតែយល់ណា ចេះថាធ្វើម៉េចបើគាត់ចង់ហើយ ឲ្យគាតទៅៗជូនគាត់ទៅ ។

ធានី : ហើយគាត់ឲ្យជាសោហ៊ុយ?

ទូក : បាទ! ឲ្យជាសោហ៊ុយឲ្យយើងខ្លះ ។

ធានី : កាលនឹងគេចាយជាមាស?

ទូក : ចាយជាមាស ហើយនឹងលុយបាត លុយខ្មែរយើងមានក្រដាស់ម៉ាកាក់ ២កាក់ ៥រៀល ពីជំនាន់នឹងនោះ ។

ធានី ៖ ហើយកាលនឹងគេឲ្យ ពេលពូជូនទៅម្ដងនឹងគ្នា៨-១០នាក់អញ្ចឹង?

ទូក ៖ ៨ ជួនកាល៨នាក់ ជួនកាល៥នាក់ ជួនកាល១០នាក់ ជួនកាល២០នាក់ក៏មានដែរ ។

ធានី ៖ ហើយដល់ពេលជូនម្ដងៗ គេឲ្យប៉ុន្មានដែរទៅ?

ទូក ៖ បើមាសអត់ហើយ ៥ជីម៉ាវ៉ូងនឹង ម្ដងៗ ធ្វើម៉េចឲ្យមកដល់ព្រំដែន ។ ហើយម៉ាជិនាន់នឹង បានគាត់រត់ទៅអត់រួចនោះ ម៉ាជិនាន់ក-៥ គេដាក់មីនណា គេដាក់មីនតាមព្រំដែន ហើយ អញ្ចឹងទៅពួកខ្ញុំដោះមីន ឆ្លងគាត់មកដីខ្មែរនឹង ច្រកត្រង់ណាៗពួកខ្ញុំដឹង ដល់អញ្ចឹងគាត់បេះ តែពឹងពាក់បេះតែជូនទៅ ។

ធានី ៖ អញ្ចឹងពូរបៀបដូចថាដោះមីនហើយ ជូនរបស់គាត់ យើងដឹងស្គាល់ផ្លូវ?

ទូក ៖ បាទ!

ធានី ៖ ជូនប៉ុន្មានដងដែរពូ?

ទូក ៖ អឺ! ច្រើនណាស់ ៨-១០-២០ដងនោះ វាមិនសូវចាំដល់វាយូរមិនបានគិតអារឿងអញ្ចឹង ដង ។

ធានី ៖ នៅតែឆ្នាំ៧៩ដដែល?

ទូក ៖ ហ៊ឺ! ឆ្នាំ៨០ក្នុងកំឡុងឆ្នាំ៨០ កំឡុងអា៨១នឹងហើយ ។

ធានី ៖ ៨១?

ទូក ៖ បាទ! ៨១ ៨២នឹងម្ដុំនឹងរហូតនឹង ។

ធានី ៖ អញ្ចឹងពេលជូនអញ្ចឹង អស់ច្រើនថា៥ជី ហើយអញ្ចឹងអត់មានជាអីផ្សេងទៀតទេ?

ទូក ៖ អត់ទេ ។

ធានី ៖ ហើយគ្នាពូទៅប៉ុន្មាននាក់ ជូនគាត់ម្ដងៗ?

ទូក ៖ កាល១០-២០នាក់ដែលជូន ។

ធានី ៖ ជូន៤-៥នាក់នឹង?

ទូក ៖ បាទ!

ធានី ៖ ម៉េចក៏ជូនច្រើនៗម៉េច?

ទូក ៖ ចុះបើទៅប៉ះកាលទាហាន ឬក៏យួនបាញ់តាមផ្លូវទៅ វាពិបាកដែរ មុននឹងជូនយើងការពារ គេអះអាងហើយបានយើងយករបស់គេ យកមាសគេប៉ុននឹង ការ៥ជីនឹង យើងការពារ អាយុជីវិតគេ ។ អាម៉ាក្រុមដើរទៅស៊ើបការណ៍មុនទៅ អាម៉ាក្រុមជូនមនុស្សទៅអញ្ចឹងឯង ។

ធានី ៖ ហើយមេរបស់ពូអីអត់យល់ទាស់អី?

ទូក ៖ ចុះគាត់នៅតូចៗ សិទ្ធិត្រឹមកងធំអីដែលមានរឿងរ៉ាវអីប្រាប់គាត់តាមត្រង់ទៅ ។

ធានី ៖ គាត់អនុញ្ញាតិឲ្យដែរ?

ទូក ៖ បាទ!

ធានី ៖ ចុះពេលពូធ្វើអ្នកដឹករទេះ ដែលធ្លាប់ឃើញគេនាំមនុស្សបណ្ដើរទៅ ឬធ្លាប់អីទេ ព្រោះពូជាអ្នកដឹករទេះ ដឹកអាហារអីដែរ?

ទូក ៖ ខ្ញុំអត់ដែលឃើញគេចាប់គេចងដែរពីមុន តែគ្រាន់បើគេធ្វើចុះគេមិនឲ្យយើងដឹងដែរ យើងមនុស្សតូចតាចអី ។

ធានី ៖ តែពូធ្លាប់អ្នកដើរអីបានដើរឆ្ងាយ?

ទូក ៖ អត់ទេ អត់ដែលបានឃើញទេ តាមសូម្បីតែពុកខ្ញុំគេចាប់ទៅ ខ្ញុំមិនទាំងដឹងគេចាប់គាត់ទៅជង់នឹង ។

ធានី ៖ ចុះអ្នកផ្សេងទៀតនៅក្នុងភូមិពូអីអញ្ចឹង អាពេលនឹងពូមិនដូចថាគេហៅថាអ្នកចាស់ស្រុកមែនទេ ហើយឃើញអ្នកថ្មីៗនឹង ពូដែលធ្លាប់ឲ្យអីគាត់ហូប ឬក៏ជួយអីមួយចិត្តគាត់ថាម៉េចទេ?

ទូក ៖ អូ! អានឹងមានតើ ជួនកាលគេមករកដូចយើង ជួនកាលយើងដឹកខ្នុរអញ្ចឹងគាត់មកសុំអី អ្នកធ្វើដំណើរថ្មីៗនឹង យើងឲ្យនឹងហើយ ផ្លែខ្នុរ៤-៥ទៅគាត់ចែកគ្នាគាត់ហូបទៅ ។

ធានី ៖ គាត់មានពីខាងណាវិញ អ្នកសុំនឹង?

ទូក ៖ អ្នកសុំនឹងដូចខ្ញុំថា ពួកជម្លៀស១៧មេសានឹង ។

ធានី ៖ មកពីភ្នំពេញ?

ទូក ៖ មកពីភ្នំពេញ គាត់ស្គាល់ខ្ញុំ គាត់ថាអាល្អិតក្មួយអឺសុំខ្នុរ២-៣បានអត់ ខ្ញុំដឹងខ្ញុំឲ្យហើយ គាត់ហើយម្យ៉ាងនៅស្រុកនឹងវាសំបូរផ្លែខ្នុរសំបូរអីដែរ ចង់និយាយថាទុំ បើទុំតាមដើម តាមអីនឹងគឺយើងទៅឃើញបេះយកមកក៏គេអត់ថាអីដែរ ។

ធានី ៖ ពូបេះបាន?

ទូក ៖ ខ្ញុំបេះបានតើ ពីសម័យនោះ ។

ធានី ៖ អញ្ចឹងពូបានបេះយកហូប យកអីបាន ឬក៏គេបេះយកទៅណា?

ទូក ៖ បេះនឹង យកមកឲ្យចាស់ៗដែលគាត់ធ្វើការផារនឹង តែគ្រាន់ជួបតាមផ្លូវអី គាត់ដើរមកសួរដឹកអី ដឹកខ្នុរ អឺសុំ២-៣បានអត់ យើងឲ្យគាត់ទៅ ។

ធានី ៖ ប៉ុន្មានដងដែរ ពូ?

ទូក ៖ អារឿងដឹងនឹងគិតវាមិនគ្រប់ទេ ពីសម័យនឹងវាភ្លេចដែរ ប៉ុនខ្ញុំធ្លាប់ឲ្យគេហូបច្រើនដែរ តាំងពីក្មេងៗគេបាននៅយើងនឹង ឲ្យដឹកម៉ាររទេះមកអញ្ចឹងទៅជួបក៏ឲ្យ១-២កញ្ជើរទៅ ។

ធានី ៖ ហើយពេលដែលពូឲ្យមងៗ អ្នកដែលនេះនឹង ដូចថាមេរបស់ពូអីអត់ស្ដីអីពូឬយ៉ាងម៉េច?

ទូក :	អត់ទេ ចាស់ៗនៅជាមួយគាត់ ចាស់ហើយគាត់ម៉េចនឹងស្ដីឲ្យប៉ុនៗនឹង ។

ធានី :	អ្នកដែលពូនៅជាមួយនឹងគាត់ឈ្មោះអីគេ?

ទូក :	គាត់ស្លាប់ហើយឈ្មោះតាបៀន ប៉ុនគាត់ស្លាប់ហើយឥឡូវនេះ ។

ធានី :	គាត់មានស្រុកកំណើតនៅជាមួយពូ?

ទូក :	មែនទែន គាត់តាខ្ញុំទៀត ។

ធានី :	តាពូ?

ទូក :	បាទ!

ធានី :	តាបង្កើត ឬក៏?

ទូក :	មិនមែនទេ តាជីដូនមួយ ។

ធានី :	ហើយអញ្ចឹងក៏នៅជាមួយពូ គេសុំពូ ឬក៏គេសុំតា?

ទូក :	ខ្ញុំក៏គាត់សុំ តានឹងក៏គេសុំគាត់ដែរ អញ្ចឹងគាត់ឲ្យខ្ញុំកើបយកទៅឲ្យទៅប៉ុនណាៗ គាត់ប្រាប់យើងឲ្យប៉ុននឹងទៅ ។

ធានី :	ដល់ពេលជយម្ដងៗអញ្ចឹង តើដូចអារម្មណ៍របស់ពូយល់ថាម៉េចដែរ?

ទូក :	ខ្ញុំក៏មិនសូវយល់ដែរពីសម័យនឹង គ្រាន់ចាំពាក្យទុកថា យើងឲ្យគេហូប គេអរគុណហើយអានឹង“អរគុណហើយក្អួយ” ប៉ុននឹងគ្មានស្អីទៀត ពីជំនាន់នឹង តែចង់និយាយថាពាក្យខ្មែរយើង តែប៉ុននឹងយើងអរសំបើមណាស់ ពីជំនាន់នោះហើយយើងទៅមានស្អីចែកគ្នា ហើយម្យ៉ាង ខ្មែរយើងម៉ាជំនាន់នោះមិនទាន់ទៅចេះដឹងដូចឥឡូវណា មែនទែនយើងវា ទាំងគេទាំងខ្ញុំ គ្មានដឹងខ្យល់អីផងកាលនឹង គ្រាន់ពាក្យអរគុណម៉ាម៉ាត់នឹង មិនដឹងថាពាក្យស្អីទេ បើយើងនិយាយឲ្យដល់វាទៅនឹង ។

ធានី :	ប៉ុន្តែពូចេះតែយកឲ្យគេទៅ?

ទូក :	បាទ! ចុះធម្មតាទេ យើងសុំហើយ យើងមិនឲ្យវាមិនកើត ចេះតែចែកគ្នារស់ទៅ ។

ឆាយ :	ធ្លាប់ជួយជាស្រូវ ជាអង្ករអីដល់គាត់?

ទូក :	អត់ទេ ស្រូវអង្ករមិនដែលទេ តែបើថារបស់ហូបដូចជាខ្ទុរ ដូចជាស្វាយ ដូចជាពោតអីធ្លាប់មានដំឡូងអីនឹង ។

ធានី :	ហើយកាលនឹងពូដឹកពីណាទៅណាខ្លះ បានមានអ្នកសុំ?

ទូក :	ដឹកចេញពីកន្លែងឃុំនឹងទៅភូមិអូរតាសេក ស្រុកកំណើតខ្ញុំនឹង ។

ធានី :	ឃុំណា?

ទូក :	ដឹងពីឃុំអូរម្ជូនឹង ។

ធានី ៖ ឃុំអូរម្លូ ក្នុងស្រុកអីដែរ?

ទូក ៖ ឃុំអូរម្លូ ស្រុកស្ទឹងត្រង់ ។

ធានី ៖ ស្រុកស្ទឹងត្រង់ ហើយទៅ?

ទូក ៖ ដឹកទៅភូមិអូរតាសេក អូរឫស្សីនៅជិតគ្នានឹង ។

ធានី ៖ អញ្ចឹងដឹកទៅដឹកមករាល់តែដើងនឹង?

ទូក ៖ ដឹកទៅ ជួនកាលយើងដឹកពីជនបទមក យើងដឹកជន្ទោះ ដឹកអាដែលខ្សែគេវិញខ្សែបរទេះ បរអីអញ្ចឹង អញ្ចឹងយើងដឹកមកឲ្យកន្លែងសន្តាត់នឹង ពេលសន្តាត់នឹងគេសួរយើងត្រូវការអី ត្រូវការផ្លែក្រូច ឬក៏ខ្នុរអី គេថាឲ្យទៅជួបអ្នកចំការបេះដាក់មួយរទេះទៅ គេដឹកជូរគ្នាទេ ។ ឬក៏ដល់ ខបមាថាម៉ាខែនឹងដឹកអង្ករតែម្តង ដឹកអានឹងមក ដឹកអង្ករយកទៅវិញ ។

ធានី ៖ ហើយខាងណាអ្នកបញ្ជាឲ្យពូដឹកអស់នឹងមក?

ទូក ៖ អានឹងតាខ្ញុំគាត់អ្នកជួបប្រធានសន្តាត់នឹងហើយ ។

ធានី ៖ ហើយប្រធានសន្តាត់នឹងឈ្មោះអីគេ?

ទូក ៖ ដឹងឈ្មោះអីជង ខ្ញុំអត់ស្គាល់ផងកាលនឹង ។

ធានី ៖ ប្រធានសន្តាត់ដែលចាប់ឪពុកពូនឹង?

ទូក ៖ បាទ!

ធានី ៖ អញ្ចឹងអរគុណពូម្តងទៀត ។ អញ្ចឹងភូមិនឹងគេហៅភូមអីដែរ?

ទូក ៖ ទួលស្វាយ ។

ធានី ៖ ឃុំ?

ទូក ៖ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ធានី ៖ លេខទូរស័ព្ទពូលេខប៉ុន្មានដែរ?

ទូក ៖ ០៩៧ ៧៥ ៣៣ ៨៦ ។

ធានី ៖ តែមួយនឹង?

ទូក ៖ បាទ!

ធានី ៖ អញ្ចឹងអរគុណពូច្រើន ។

ទូក ៖ គេសួរថាចុះឯណាពុកយើងនៅណា ខ្ញុំព្តតែគេថាគេចាប់ពុកខ្ញុំដឹងគេចាប់ដាក់ថ្ងៃណា ថាពុកជាប់គុកបាត់ហើយ ក៏បងខ្ញុំគាត់ទៅតវ៉ានៅកន្លែងសន្តាត់ ក្រោយមកគេប្រាប់ថាចាំឲ្យគាត់មកវិញ ។ ដល់ពេលឲ្យគាត់មក បងខ្ញុំបាត់ឈឹងទល់សព្វថ្ងៃនេះទៅ បងប្រុសខ្ញុំមួយទៀតតែគាត់នៅព្រំដែនយួននោះទេ វៃយួន ។

ធានី ៖ បងពូធ្វើទាហានខ្មែរក្រហមដែរ?

ទូក ៖ បាទ!

ធានី ៖ ហើយទៅវៃព្រំដែនឆ្នាំ៧៨នឹង គាត់ត្រឡប់មកវិញ?

ទូក ៖ បាទ! ដល់ពេលគាត់ត្រឡប់មកលេងផ្ទះនេះ គាត់សួរថាឯណាពុកយើង គាត់មកសួរខ្ញុំ គាត់មកជួបខ្ញុំមុនគេ ខ្ញុំថាពុកណា ពុកគេចាប់ដាក់គុកបាត់ហើយ ខ្ញុំមិនដឹងថាគេចាប់គាត់ផង ។ ក៏អញ្ចឹងក៏គាត់ទៅតវ៉ានៅកន្លែងសង្កាត់គេនឹង ថាទោះបីទៅយកគាត់ទៅដូរក៏ដោយ ឲ្យតែយកពុកខ្ញុំមកវិញ តាំងពីនឹងទៅក៏បាត់សូន្យបណ្តោយទៅ នឹងបងប្រុសខ្ញុំ ។

ឆាយ ៖ ពេលនឹងបងប្រុសនឹងមានសារថាទៅសមរភូមវិញ ទៅអង្គភាពវិញ?

ទូក ៖ បាទៗ ។

ធានី ៖ អញ្ចឹងគាត់មិនមែនមកពីភូមិនឹងអ្នកចាប់ទេ គាត់ទៅវៃ?

ទូក ៖ គាត់ទៅព្រំប្រទល់ទៅស្រុកយួនវិញនឹង ។

ធានី ៖ ទៅវៃបន្ត?

ទូក ៖ បាទ!ទៅវៃព្រំដែនវិញនឹង ក៏ទៅបាត់ឈឹងរហូតទល់សព្វថ្ងៃនឹង រកក៏រកមិនឃើញ សួររកខ្លាចគាត់នៅខ្ញុំស៊ើបសួរបាត់សូន្យបណ្តោយ ខ្ញុំកំណត់ថាស្លាប់ហើយសម័យនេះរកមិនឃើញហើយ ។

ធានី ៖ បងពូឈ្មោះអីដែរ?

ទូក ៖ បងខ្ញុំឈ្មោះជឿន ប៉ុនមិនដឹងគាត់ដាក់ត្រកូលអី មិនដឹងជាដាក់ជីន មិនដឹងជាដាក់ស្អី ខ្ញុំមិនបានសួរគាត់ដែលអញ្ចឹង ។

ធានី ៖ ហើយចុះពូពេលក្រោយៗបែក៧៩អីអញ្ចឹង ពូដែលទៅលេងស្រុកកំណើត?

ទូក ៖ អត់ដែលបានទៅទេ ពី៧៩មក ៨០ ៨១ ៨២ កំពុងពេញវៃគ្នាតាមព្រំដែនវៃមករហូត ។

ធានី ៖ អញ្ចឹងដើមឆ្នាំប៉ុន្មានដែលពូបានទៅលេងស្រុកកំណើត?

ទូក ៖ ខ្ញុំទើបទៅឆ្នាំ២០០០ហើយនឹង ។

ធានី ៖ ហើយចុះឪពុកម្តាយពូទៅដែរ?

ទូក ៖ ស្លាប់ៗយូរហើយ ស្លាប់តាំងពីឆ្នាំ៩៧ ពុកខ្ញុំស្លាប់ឆ្នាំ៩៧ ។

ធានី ៖ ដោយសារអីដែរ?

ទូក ៖ គាត់ឈឺចាស់ខ្លួនគាត់ទេ ។

ធានី ៖ មិនមែនមកពីគេវៃគាត់ទេ?

ទូក ៖ វាទារុណទារាជពីសម័យនឹងខ្លះនឹងហើយ ដែលគាត់ស្លាប់ ។

ធានី : ចុះម្ដាយ?

ទូក : ម៉ែខ្ញុំគាត់ឈឺគ្រុនចាញ់តាមមើល បានស្លាប់ សង្គមនេះក្រីក្រដែរ ។

ធានី : សព្វថ្ងៃពូរៀនបានដល់ត្រឹមណាដែរ?

ទូក : ខ្ញុំ អឺ! បើសរុបទៅរៀនមិនបានច្រើន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរៀនថ្នាក់ទី៤ទី៥ នឹង ។

ធានី : រៀននៅក្នុងកម្ពុជាប្រជាធិបតេយ្យនឹងម៉ង?

ទូក : បាទ! រៀនតាមព្រំដែននឹង ។

ធានី : ក្រោយពី៧៩ហើយបានពូរៀន ឬក៏ក្នុងកំឡុងពេល?

ទូក : ក្រោយ៧៩មកហើយ ។

ធានី : បានពូរៀន?

ទូក : បាទ! រៀនផងដើរច្បាំងផងរហូត ដែលទំនេរ មិនមែនដូចយើងក្នុងមានមនុស្សច្រើនឯណា ។ ខាងក្រៅមិនងាយទេ យើងរៀនបានប៉ុនៗនឹង ថាយើងនៅមិនបានទេ ត្រូវទៅស្នេហាជាតិតស៊ូខ្លះ ប៉ុនៗនឹងបានហើយ ។

ធានី : កាលពេលបង្រៀននឹងមានគ្រូនៅ?

ទូក : មានគ្រូត្រឹមត្រូវ ។

ធានី : គ្រូដែលធ្វើទ័ពដូចពូដែរ ឬមួយក៏?

ទូក : គ្រូកងទ័ពនឹង ប៉ុនណាបើនិយាយថាវិកងទ័ពគាត់ចេះគ្រាន់បើដែរ បានពួកខ្ញុំរៀនចេះដែរ បើគ្រូអន់ៗក៏រៀនមិនចាំ ។

ធានី : គ្រូឈ្មោះអី គ្រូបង្រៀន?

ទូក : គ្រូឈ្មោះបងខា ។

ធានី : អីគេខា?

ទូក : ដឹងត្រកូលគាត់ឈ្មោះអីទេ ខ្ញុំភ្លេចបាត់ហើយ ប៉ុនឥឡូវនេះ គាត់នៅកំរៀង ។

ធានី : នៅកំរៀងៗបាត់ដំបង?

ទូក : បាទ! លេខទូរស័ព្ទគាត់ភ្លេចហើយមកcallថ្ងៃមុន ។

ធានី : អញ្ជើងអរគុណពូ ។

«ចប់»